**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:...០៦៧...សរណន**

# សារាចរណែនាំ
## ស្តីពី
## ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

អនុលោមតាម ព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃ ដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូលនិងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំអំពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដូចតទៅៈ

១- សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកលើមុខទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ជាធរមាន។

២- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍ និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ ឬទំនិញប្រើរួចគ្រប់ប្រភេទ មិនស្ថិតក្រោមវិសាលភាពអនុវត្តនៃការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឡើយ។

៣- ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការកត់ត្រាទទួលស្គាល់លិខិតប្រគល់សិទ្ធិនាំចូលជាទំនិញពាក់ម៉ាកផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន។

៤- អ្នកទិញយកទៅប្រើប្រាស់ ឬដេប៉ូលក់ចែកចាយបន្ត អាចទិញទំនិញពីអ្នកចែកចាយប្រចាំបណ្តាខេត្ត រាជធានី ឬតំបន់ផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការរើសអើង។ ក្នុងករណីដែលក្រសួងមានសមត្ថកិច្ចរកឃើញថា ក្រុមហ៊ុនណាមួយអនុវត្តផ្ទុយនឹងការណែនាំនេះ នឹងត្រូវបានធ្វើមោឃភាពនូវលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬទទួលទោសប្បញ្ញត្តិចែងក្នុងមាត្រាច្បាប់ជាធរមាន។

៥- ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសកំណត់នីតិវិធីលម្អិតស្តីពី ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឲ្យមានអនុលោមភាពតាមកិច្ចព្រមព្រៀងអន្តរជាតិ បញ្ញត្តិនៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងស្របតាមសារាចរណែនាំនេះ សំដៅធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ និងបម្រើឲ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦- ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចុះណែនាំដល់ក្រុមហ៊ុន អាជីវករ និងប្រជាជន អំពីខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឲ្យបានទូលាយ និងអនុវត្តក្នុងដែនសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព និងប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ